**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា**
**ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**

# សេចក្តីប្រកាសព័ត៌មាន

គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមជម្រាបជូនព័ត៌មានដល់សាធារណជន ជាពិសេសពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដូចខាងក្រោម៖

១. បច្ចុប្បន្ន គណៈកម្មការបានបោះពុម្ព លិខិតឆ្លងដែន/លិខិតធ្វើដំណើរពលករកម្ពុជាទៅធ្វើការនៅបរទេស និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេសចំនួន ២៣១ ៦២៦នាក់ និងបានត្រៀមទទួលស្វាគមន៍ជានិច្ចដើម្បីបើកផ្តល់សំណុំលិខិតទាំងនេះជូនដល់ពលករកម្ពុជាទៅតាមនីតិវិធី ដែលភាគីថៃបានកំណត់។

២. មានតែពលករកម្ពុជា ដែលទទួលបានសំណុំលិខិតស្របតាមនីតិវិធី ដែលភាគីថៃបានកំណត់ប៉ុណ្ណោះ ទើបអាចយកសំណុំលិខិតទាំងនេះទៅទទួលបានភាពស្របច្បាប់ពីអាជ្ញាធរថៃ។

៣. ចាប់ពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលភាគីថៃអនុញ្ញាតឱ្យភាគីកម្ពុជាវិលត្រឡប់ទៅបើកផ្តល់សំណុំលិខិតទទួលបានភាពស្របច្បាប់ជូនពលករកម្ពុជាយើងវិញ ស្របតាមស្មារតីនៃលទ្ធផលកិច្ចប្រជុំរបស់គណៈរដ្ឋមន្ត្រីថៃ (ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦)នោះ លេខាធិការដ្ឋានរបស់គណៈកម្មការប្រចាំនៅទីក្រុងបាងកកបានទទួលសំណើសុំដកសំណុំលិខិតចំនួន ៤ ៥៣៤សំណើ និងបានបើកផ្តល់ចំនួន ៤ ១០២សំណុំ។

៤. យោងតាមស្មារតីសេចក្តីជូនដំណឹងលេខ ០២៣/១៦គ.ផ.ថ/ស.ជ.ណ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់គណៈកម្មការ ដើម្បីទទួលបានសំណុំលិខិតនេះ ពលករម្នាក់ៗត្រូវយកប័ណ្ណព័ណ៌ស៊ីជម្ពូ ដែលបានធ្វើបច្ចុប្បន្នកម្មជាមួយអាជ្ញាថៃក្នុងចន្លោះថ្ងៃទី០១ ខែមេសា ដល់ថ្ងៃ២៨ ខែកក្កដា ឆ្នាំ២០១៦ មកបង្ហាញជូនលេខាធិការដ្ឋានរបស់គណៈកម្មការ ដែលមានអាសយដ្ឋាននៅក្នុងស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជានៅក្នុងទីក្រុងបាងកក។ ពលករដែលមានអាសយដ្ឋានឆ្ងាយ ក៏អាចស្នើសុំដកសំណុំលិខិតនេះតាមរយៈគេហទំព័រ www.cambodianworker.net ផងដែរ។ លេខាធិការដ្ឋាន នឹងបើកផ្តល់សំណុំលិខិតនេះក្នុងរយៈពេល១៤ថ្ងៃនៃថ្ងៃធ្វើការ។ និយោជក ឬតំណាងនិយោជកដែលបានចុះបញ្ជី និងទទួលស្គាល់ពីអាជ្ញាធរថៃក៏អាចស្នើសុំដកសំណុំលិខិតនេះក្នុងនាមពលករ តាមរយៈគេហទំព័រខាងលើបានដែរ ប្រសិនបើនិយោជក ឬតំណាងនិយោជកនោះមានលិខិតប្រគល់សិទ្ធិពីពលករ។

៥. តាមការឯកភាពរវាងភាគីថៃនិងកម្ពុជា សាមីពលករត្រូវបង់កម្រៃសេវាបើកផ្តល់ចំនួន៩៥០បាត ជូនគណៈកម្មការ និងចំនួន៥០០បាត ជូនការិយាល័យអន្តោប្រវេសន៍ថៃ។ ដោយឡែកនិយោជកឬតំណាងនិយោជក ដែលទទួលបានការប្រគល់សិទ្ធិពីពលករ ត្រូវស្នើសុំបញ្ជាក់ភាពជាតំណាងនេះពីមន្ទីរការងារថៃ ឬអាជ្ញាធរថៃ ឬមន្ទីរសាការីថៃបន្ថែមទៀត។ ជាទូទៅនៅពេលជម្រាបជូនពលករអំពីតម្លៃសេវា គឺនិយោជក ឬតំណាងនិយោជកអាចប្រាប់ទៅបងប្អូនពលករអំពីតម្លៃសេវាម៉ៅការ ដែលមានបូកបន្ថែមថ្លៃធ្វើដំណើរ និងថ្លៃដឹកជញ្ជូនផ្សេងទៀតរបស់ខ្លួន។

៦. ដើម្បីទប់ស្កាត់និយោជក ឬតំណាងនិយោជក ឬជនឱកាសនិយមក្នុងការយកថ្លៃសេវាលើសពីកម្រៃសេវាផ្លូវការដែលភាគីថៃនិងភាគីកម្ពុជាបានឯកភាពគ្នា និងដើម្បីបង្កើនល្បឿនក្នុងការបើកផ្តល់សំណុំលិខិតទទួលភាពស្របច្បាប់នេះគណៈកម្មការបាននឹងកំពុងស្នើសុំការអនុញ្ញាតពីភាគីថៃ ដើម្បីឱ្យមន្ត្រីនៃគណៈកម្មការអាចធ្វើដំណើរទៅបើកផ្តល់សំណុំលិខិតនេះនៅកន្លែងធ្វើការរបស់ពលករកម្ពុជាផ្ទាល់តែម្តង ឬបើកផ្តល់នៅតាមបណ្តាស្រុកនៃខេត្ត ដែលមានពលករកម្ពុជាកំពុងធ្វើការ។

៧. ក្នុងរយៈពេលរងចាំការឆ្លើយតបរបស់ភាគីថៃ គណៈកម្មការសូមអំពាវនាវដល់បងប្អូនពលករបង្កើនស្មារតីប្រុងប្រយ័ត្ន និងសូមសាកសួរព័ត៌មានឱ្យបានច្បាស់អំពីប្រភេទតម្លៃសេវា ដែលត្រូវបង់ទៅភាគីកម្ពុជា និងទៅភាគីថៃ ចៀសវាងនិយោជក ឬតំណាងនិយោជកខិលខូចមួយចំនួន ឬជនឱកាសនិយមភូតកុហកដោយពេលជួបភាគីថៃថាត្រូវបង់សេវាលើសមកភាគីកម្ពុជា ពេលជួបភាគីកម្ពុជាថាត្រូវបង់លើសទៅភាគីថៃ។

៨. កន្លងទៅនេះគណៈកម្មការ និងស្ថានឯកអគ្គរាជទូតកម្ពុជាបានជូនដំណឹង និងបានស្នើសុំទៅភាគីថៃឱ្យចាត់វិធានការតាមផ្លូវច្បាប់ភ្លាមៗ ក្នុងករណីមានជនណាមួយយកកម្រៃសេវាលើសចំនួន ដែលភាគីទាំង២ បានឯកភាពគ្នា។

៩. ក្នុងករណីសាធារណជន ឬបងប្អូនពលករបានឃើញ ឬបានដឹងថាមានជនណាមួយយកកម្រៃសេវាលើសពីការកំណត់នោះ សូមមេត្តាផ្តល់ដំណឹង ឬប្តឹងមកគណៈកម្មការតាមរយៈទូរស័ព្ទលេខ +៦៦ ៨៦ ៧៩៩ ៩៩៥៧, +៦៦ ៩៤ ០៩២ ៥៩០៥, +៦៦ ៨២ ៧៧៧ ៧២១៥, +៦៦ ២ ៩៥៧ ៥៨៥១ ឬប្តឹងទៅមន្ទីរការងារថៃ ឬប្តឹងទៅមន្ត្រីប៉ូលីសថៃដែលនៅក្បែរនោះជាបន្ទាន់។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមសាធារណជន ជាពិសេសពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃមេត្តាជ្រាបជាព័ត៌មាន និងសូមចូលរួមសហការទប់ស្កាត់ករណីអវិជ្ជមាននានាក្នុងការបើកផ្តល់សំណុំលិខិតទទួលភាពស្របច្បាប់នេះ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧